# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-May-2011, 15:32
CMS/CFO: Kauv Keoratanak

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "សំណើរបស់ អៀង សារី សុំឲ្យមានសេចក្តីសម្រេចជាបន្ទាន់ទៅលើបញ្ហាជាក់លាក់មួយចំនួនដែលបានលើកឡើង នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ"

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ជនជាប់ចោទ និង មេធាវីការពារក្តី** |
|---|---|---|
| **សហព្រះរាជអាជ្ញា:** | **អង្គជំនុំជម្រះសាលាដំបូង:** | **ជនជាប់ចោទ:** |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | ខៀវ សំផន |
| | ចៅក្រមJean-Marc LAVERGNE | អៀង ធីរិទ្ធ |
| | ចៅក្រម យូ អុតតារា | |
| | | **មេធាវីការពារក្តីជនជាប់ចោទ:** |
| | **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:** | លោក សុន អរុណ |
| | ពេជ អង្គ | លោក Michiel PESTMAN |
| | Elisabeth SIMONNEAU FORT | លោក Victor Koppe |
| | | លោក អាង ឧត្តម |

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ*

លោក Michael G.KARNAVAS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក ស សុវាន
លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១. នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ អៀង សារី តាមរយៈមេធាវីការពារក្តីរបស់ខ្លួន ("មេធាវីការពារក្តី") បានដាក់ "សំណើរបស់ អៀង សារី សុំឲ្យមានសេចក្តីសម្រេចជាបន្ទាន់ទៅលើបញ្ហាជាក់លាក់មួយចំនួនដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ"[1] (សំណើ")។ មេធាវីការពារក្តីស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ចេញសេចក្តីសម្រេចជាបន្ទាន់ចំនួន២។ ទី១ ពួកគេស្នើថា ក្រុមមេធាវីការពារក្តីនិមួយៗ គួរតែបានអនុញ្ញាតពេលវេលាស្មើៗគ្នា ដូចបានផ្តល់ជូនសហព្រះរាជអាជ្ញាដែរ សម្រាប់ធ្វើសេចក្តីសន្និដ្ឋានអំពីការចោទប្រកាន់។ ពួកគេនិយាយថា រយៈពេល២ម៉ោង នឹងគ្រប់គ្រាន់ហើយសម្រាប់សហព្រះរាជអាជ្ញា និងថាបើដូច្នេះ ពួកគេទាមទាររយៈពេលរួមគ្នា ៨ម៉ោង សម្រាប់ក្រុមមេធាវីការពារក្តីទាំងបួនក្រុម[2]។ ទី២ មេធាវីការពារក្តីស្នើថា ភាគីនានាអាចជួបសាក្សី និងអ្នកជំនាញ ដើម្បីពិភាក្សាអំពីខ្លឹមសារនៃសក្ខីកម្មរបស់ពួកគាត់ មុនពេលចូលបង្ហាញខ្លួននៅតុលាការ។ ពួកគេតវ៉ាថា ការណ៍នេះនឹងជួយលើការផ្តោតការយកចិត្តទុកដាក់របស់មេធាវីការពារក្តី ក្នុងការតាំងសំណួរនៅពេលសវនាការ និងធានាបាននូវសមភាពនៃមធ្យោបាយតទល់ក្តីរវាងភាគីនានា[3]។

២. សហព្រះរាជអាជ្ញាយល់ព្រមជាមួយនឹងមេធាវីការពារក្តីដែលថា សេចក្តីសម្រេចជាបន្ទាន់នឹងជួយដល់ភាគីក្នុងការត្រៀមរៀបចំផ្សេងៗរបស់ខ្លួនសម្រាប់សវនាការ។ ទោះជាយ៉ាងណាក្តី ដូចមូលហេតុបញ្ជាក់ខាងក្រោមនេះ សហព្រះរាជអាជ្ញាស្នើសុំបដិសេធចោលសំណើនេះ និងទទួលយកគោលជំហរកែប្រែរបស់សហព្រះរាជអាជ្ញាចំពោះបញ្ហាដ៏សំខាន់ទាំង២នេះ។

## II. សេចក្តីសន្និដ្ឋានអំពីការចោទប្រកាន់

### ក. សារសំខាន់នៃសេចក្តីសន្និដ្ឋានអំពីការចោទប្រកាន់

៣. មេធាវីការពារក្តីស្នើថា សហព្រះរាជអាជ្ញាទទួលបានរយៈពេល២ម៉ោង សម្រាប់ធ្វើសេចក្តីសន្និដ្ឋានអំពីការចោទប្រកាន់ ខកខានមិនបានគិតគូរពីសារសំខាន់នៃសេចក្តីសន្និដ្ឋាន ទំហំ និងវិសាលភាពនៃករណីនេះទេ។ សេចក្តីសន្និដ្ឋានអំពីការចោទប្រកាន់ គ្រាន់តែជាឱកាសមួយសម្រាប់សវនាការនេះ ដើម្បីឲ្យសហព្រះរាជអាជ្ញាផ្តល់រូបភាពច្បាស់លាស់អំពីភ័ស្តុតាង ច្បាប់ និងខ្លឹមសារជាគន្លឹះនានាជូនអង្គជំនុំជម្រះសាលាដំបូង និងសាធារណជនទូទៅរហូតដល់ពេលធ្វើសេចក្តីសន្និដ្ឋានបិទ

---

[1] ឯកសារលេខ: E87, "សំណើរបស់របស់ អៀង សារី សុំឲ្យមានសេចក្តីសម្រេចជាបន្ទាន់ទៅលើបញ្ហាជាក់លាក់មួយចំនួន ដែលបានលើកឡើងនៅឯកិច្ចប្រជុំរៀបចំសវនាការ" ("សំណើ"), ១១ ឧសភា ២០១១, ERN 00686787-00686790 ។

[2] សំណើ, ទំព័រទី២ ។ ទោះបីជាមេធាវីការពារក្តីបានស្នើសុំពេល១០ម៉ោងក៏ដោយ ការណ៍នេះហាក់ដូចជាដើម្បីបញ្ចូល២ម៉ោងសម្រាប់ការិយាល័យសហព្រះរាជអាជ្ញា ។ ដូចនេះវាទុកពេលរួមបញ្ចូលគ្នាសម្រាប់ក្រុមមេធាវីការពារក្តីរហូតដល់៨ ម៉ោង ។

[3] សំណើ, ទំព័រទី២ ។

ការពិភាក្សាដេញដោលតែប៉ុណ្ណោះ។ ពេលវេលាគ្រប់គ្រាន់ត្រូវបានផ្តល់ជូន ដើម្បីសម្រេចបានគោលបំណងនេះ។

៤. ប្រការដែលមេធាវីការពារក្តីមិនបានយល់ព្រមទៅនឹងអង្គហេតុណាមួយនៅក្នុងដីកាដំណោះស្រាយក្រៅពីអង្គហេតុមួយក្តាប់តូចនោះដោយមេធាវីការពារក្តី គឺត្រូវការចាំបាច់ឱ្យសហព្រះរាជអាជ្ញាទទួលបាននូវពេលវេលាគ្រប់គ្រាន់ ដើម្បីជួយដល់តុលាការ និងដល់សាធារណជន ដើម្បីឱ្យយល់ និងស្គាល់អត្តសញ្ញាណនៃភស្តុតាងដែលត្រូវលើកឡើងនូវហេតុផល ដើម្បីបង្ហាញសក្ខីកម្មអំពីអង្គហេតុដែលកំពុងតែមានបញ្ហា។ សូមជូននូវសេចក្តីសន្និដ្ឋានអំពីការចោទប្រកាន់មួយដែលមានរយៈពេលប្រាំ(៥)ម៉ោង ដែលមានភាពសមហេតុសមផល ដើម្បីឱ្យសហព្រះរាជអាជ្ញាអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការធ្វើការប្រាស្រ័យទាក់ទងរបស់ខ្លួនអំពីសំណុំរឿងនេះ។ សំណុំរឿងមួយដែលមានវិសាលភាពដ៏ធំធេងនេះ ដោយមានឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងនៅក្នុងទូទាំងប្រទេស ក្នុងអំឡុងពេលជាង៣ឆ្នាំ ដោយជនជាប់ចោទថ្នាក់ខ្ពស់ចំនួន៤នាក់ ដែលត្រូវបានចោទប្រកាន់ ដែលអនុញ្ញាតឱ្យនៅក្នុងពេលនេះ។

៥. ក្នុងរយៈពេលចំនួន៥ម៉ោងនេះគឺ សហព្រះរាជអាជ្ញាមានបំណងធ្វើការគូសបញ្ជាក់អំពីប្រធានបទ, ទឡ្ហីករណ៍, និងភស្តុតាងទាំងឡាយ ដែលគាំទ្រចំពោះធាតុផ្សំផ្នែកយុត្តាធិការនៃឧក្រិដ្ឋកម្មទាំងនេះ តួយ៉ាងដូចជា អំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធ, អំពីការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិល, អំពីលក្ខណៈ និងប្រភេទនៃព្រឹត្តិហេតុ ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់, អំពីតំណតភ្ជាប់រវាងជនជាប់ចោទទៅនឹងឧក្រិដ្ឋកម្មនានា ហើយជាពិសេសជាងនេះទៅទៀត អំពីការចូលរួមដោយផ្ទាល់របស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មទាំងនេះ។

### ខ. សមភាពនៃពេលវេលាទាក់ទងនឹងចំនួន និងចរិតលក្ខណៈនៃបញ្ហាដែលត្រូវលើកឡើង

៦. ជាការពិត មេធាវីការពារក្តីគួរបានទទួលនូវឱកាសសមាមាត្រស្មើភាពគ្នា ដើម្បីលើកបង្ហាញនូវករណីរបស់ខ្លួន តាមរយៈសេចក្តីសន្និដ្ឋានអំពីការចោទប្រកាន់មួយ បើសិនពួកខ្លួនជ្រើសរើសថាត្រូវធ្វើដូច្នេះ។ ក៏ប៉ុន្តែ សំណើដែលធ្វើឡើងដោយមេធាវីការពារក្តីដែលថា ពួកខ្លួនគួរត្រូវបានគេផ្តល់ឱ្យនូវពេលវេលាដូចគ្នាទាំងស្រុងនឹងសហព្រះរាជអាជ្ញាដែរនោះ គឺពួកគេមិនបានយកចិត្តទុកដាក់ថា សហព្រះរាជអាជ្ញាកំពុងតែលើកឡើង ដោយប្រឆាំងនឹងជនជាប់ចោទដល់ទៅ៤រូប រីឯមេធាវីការពារក្តីវិញ គឺតម្រូវឱ្យលើកឡើង ដើម្បីការពារក្តីសម្រាប់តែជនជាប់ចោទតែម្នាក់ប៉ុណ្ណោះ។ អាស្រ័យហេតុនេះ ដោយចងចាំជាប់នៅក្នុងចិត្តជានិច្ចថា សហព្រះរាជអាជ្ញាមានបន្ទុកការងារក្នុងការបង្ហាញភស្តុតាងច្រើនជាងចំនួន៤ដង ទាក់ទងអំពីការចូលរួមរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មទាំងនេះ ការដែលអនុញ្ញាតឱ្យមេធាវីជាបុគ្គលម្នាក់ៗមានទំហំពេលវេលាស្មើគ្នា គឺជាការធ្វើឱ្យមានវិសមមាត្រដោយមិនត្រឹមត្រូវរវាងភាគីនានាហើយ។

៧. បន្ថែមលើនេះ ការពិចារណាអំពីលក្ខណៈរួមរបស់ក្រុមមេធាវីការពារក្តីចំពោះធាតុផ្សំយុត្តាធិការនៃឧក្រិដ្ឋកម្ម និងអង្គហេតុធាតុផ្សំឧក្រិដ្ឋកម្មរបស់វាផ្ទាល់ ក្រុមមេធាវីការពារក្តីមិនគួរបានទទួលនូវពេលវេលាចំនួន៤ដងនៃពេលវេលាដែលបានបែងចែកឱ្យទៅសហព្រះរាជអាជ្ញា ដើម្បីដោះស្រាយបញ្ហានេះទេ។ នេះជាការណ៍សំខាន់ ដើម្បីរក្សានូវសមភាពនៃមធ្យោបាយតទល់ក្តីរវាងក្រុមមេធាវីការពារក្តី និងសហព្រះរាជអាជ្ញា ដើម្បីការពារក្តី និងដើម្បីរក្សាសមភាពនៃមធ្យោបាយតទល់ក្តីរវាងភាគីទាំង២។

៨. សំណើរបស់មេធាវីការពារក្តីដែលថា អង្គជំនុំជម្រះគួរតែផ្តល់ពេលវេលាចំនួន២ម៉ោងឱ្យទៅខាងសហព្រះរាជអាជ្ញា និង២ម៉ោងឱ្យទៅក្រុមមេធាវីការពារក្តីនីមួយៗ ដូចដែលធ្លាប់បានធ្វើនៅក្នុងសំណុំរឿងលេខ០០១[4] គឺខកខានមិនបានគិតគូរពីបញ្ហាទំហំសំណុំរឿង ដែលមានលក្ខណៈតូច និងអង្គហេតុពិតដែលថាមានជនជាប់ចោទតែម្នាក់គត់នៅក្នុងសវនាការនោះ។ ផ្ទុយទៅនឹងសំណុំរឿងនេះដែលមានទំហំធំ និងមានជនជាប់ចោទច្រើន នោះសំណើឱ្យប្រើតាមអ្វីៗដែលធ្លាប់មានពីមុនមក គឺទំនងជាតាមអំពើចិត្ត។ ក្នុងន័យតក្កភាព ការពិតត្រូវផ្ទុយពីនេះ។ សហព្រះរាជអាជ្ញាគួរទទួលបានពេលវេលាដ៏សំខាន់នេះច្រើនជាងក្រុមមេធាវីការពារក្តីនិមួយៗ ដោយហេតុថា សហព្រះរាជអាជ្ញាកំពុងតែធ្វើការចោទប្រកាន់៤ករណី មិនមែនការពារមួយករណីទេ។

## គ. សេចក្តីសន្និដ្ឋាន

៩. ជាការសន្និដ្ឋាន សហព្រះរាជអាជ្ញាមិនជំទាស់នឹងសំណើរបស់មេធាវីការពារក្តីដែលសុំពេលវេលាចំនួន២ម៉ោង ដើម្បីលើកឡើងបង្ហាញពីសេចក្តីសន្និដ្ឋានរបស់ខ្លួនពេលបើកសវនាការនោះទេ។ ទោះជាយ៉ាងដូច្នេះក៏ដោយ ពាក់ព័ន្ធទៅនឹងកត្តាទាំងឡាយខាងលើនេះ សហព្រះរាជអាជ្ញាស្នើថាពួកខ្លួនគួរត្រូវបានផ្តល់ពេលវេលាអប្បបរមាចំនួន៥ម៉ោង ក្នុងគោលបំណងដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូង និងសាធារណជនទូទៅឱ្យមានប្រសិទ្ធភាពក្នុងការយល់ដឹងពីខ្លឹមសារ សំអាងហេតុ និងភ័ស្តុតាងសំខាន់ៗនៅក្នុងសំណុំរឿង។ ក្នុងការអនុវត្ត ការណ៍នេះនឹងនៅតែមានន័យថាសហព្រះរាជអាជ្ញានឹងត្រូវមានពេលវេលាចំនួន៦០% នៃពេលវេលាដែលសរុបបញ្ចូលគ្នារបស់ក្រុមមេធាវីការពារក្តី ក្នុងការលើកបង្ហាញពីសេចក្តីសន្និដ្ឋានរបស់ខ្លួននៅពេលបើកសវនាការ។ ទាក់ទងទៅនឹងផ្នែកភ័ស្តុតាងដែលមានលក្ខណៈទូទៅដូចៗគ្នា រវាងពួកក្រុមមេធាវីការពារក្តីនៅក្នុងករណីនេះ ដូចជាភ័ស្តុតាងស្តីពីយុត្តាធិការ និងស្តីពីទីតាំងឧក្រិដ្ឋកម្មជាដើម និងស្តីពីអង្គហេតុដែលសហព្រះរាជអាជ្ញាត្រូវបានតម្រូវឱ្យលើកបង្ហាញពីករណីនានា ប្រឆាំងនឹងជនជាប់ចោទទាំង៤រូបនោះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការបែងចែកពេលវេលាបែបដូច្នេះ នឹងនាំឱ្យមានការគោរពដល់សមភាពនៃមធ្យោបាយតទល់ក្តី រវាងភាគីនានា ពាក់ព័ន្ធទៅនឹងសេចក្តីសន្និដ្ឋាននានានៅពេលបើកសវនាការ។

[4] សំណើ ត្រង់ទំព័រទី ២ ។

## III. ការស្តាប់ចម្លើយសាក្សីមុនពេលសវនាការដោយភាគី

### ក. ការស្តាប់ចម្លើយសាក្សីដោយភាគីមិនត្រូវបានអនុញ្ញាតច្បាស់លាស់ទេ នៅក្រោមច្បាប់ អ.វ.ត.ក ឬ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

១០. សំណើទី២ ដោយមេធាវីការពារក្តីដែលស្វែងរកការអនុញ្ញាត ដើម្បីទាក់ទងជាមួយសាក្សី និងអ្នកជំនាញ ដើម្បីពិភាក្សាអំពីសក្ខីកម្មរបស់ពួកគាត់ មុនពេលចូលបង្ហាញខ្លួននៅតុលាការ ត្រូវបានគេហៅជាធម្មតាថា "ការផ្តល់សក្ខីកម្មរបស់សាក្សី"នៅតាមបណ្តាតុលាការអន្តរជាតិនានា[5]។ ទម្លាប់នៃការអនុវត្តដូច្នេះមិនត្រូវបានអនុញ្ញាតទេនៅក្រោមវិធាន អ.វ.ត.ក ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[6] ឬនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង[7] ដែលប្រព័ន្ធច្បាប់កម្ពុជាយកតាមលំនាំនោះ។ តាមដែលសហព្រះរាជអាជ្ញាដឹង មិនបានអនុញ្ញាតឱ្យមានការអនុវត្ត ទាំងនៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌកម្ពុជា និងទាំងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌបារាំង។

១១. ទោះជាយ៉ាងនេះក្តី តាមរយៈមាត្រា៣៣ថ្មី អង្គជំនុំជម្រះសាលាដំបូងអាចស្វែងរកគោលការណ៍ណែនាំពីក្នុងវិធាននីតិវិធីនានាដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ប្រសិនបើ"នីតិវិធីជាធរមាន មិនពាក់ព័ន្ធនឹងបញ្ហាជាក់លាក់ណាមួយ ឬប្រសិនបើភាពមិនជាក់លាក់ទាក់ទិននឹងការបកស្រាយ ឬការអនុវត្តរបស់ខ្លួន ឬប្រសិនបើមានចម្ងល់ទាក់ទិននឹងភាពស៊ីសង្វាក់គ្នានឹងបទដ្ឋានអន្តរជាតិ[8]។ ហេតុដូច្នេះ សម្រាប់ករណីនេះ ក្រោមច្បាប់របស់ អ.វ.ត.ក "ការផ្តល់សក្ខីកម្មរបស់សាក្សី" គួរបានអនុញ្ញាត វៀរលែងតែមានបញ្ហាអំពីភាពស៊ីសង្វាក់គ្នានៃនីតិវិធីព្រហ្មទណ្ឌកម្ពុជាជាមួយនឹងបទដ្ឋានអន្តរជាតិតែប៉ុណ្ណោះ។

### ខ. ការផ្តល់សក្ខីកម្ម ជាទម្លាប់នៃការអនុវត្តជាអន្តរជាតិ ប៉ុន្តែមិនមែនជាបទដ្ឋានអន្តរជាតិនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលទេ

១២. បញ្ហាថា តើបទដ្ឋានស្តីពីការផ្តល់សក្ខីកម្មដែលមានស្រាប់នេះ បានលើកយកមកដោះស្រាយ ដោយផ្ទាល់នៅតាមបណ្តាតុលាការអន្តរជាតិនានាដែរ ឬទេ ក្នុងករណី *Lubanga*[9]។ ក្នុងករណីនេះ

---

[5] Jordash, W. "ទម្លាប់នៃការអនុវត្ត "ការផ្តល់តឹកតាង" នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ: ហេតុដូច្មេចបានជាតុលាការព្រហ្មទណ្ឌអន្តរជាតិគួរតែហាមឃាត់ទម្លាប់នៃការអនុវត្តនេះ", *Leiden Journal of International Law*, 22 (2009), ត្រង់ទំព័រ 503-505 ។

[6] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ការបោះពុម្ពផ្សាយលើកទីមួយ, ២០០៨ ។

[7] ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង, Dalloz, ការបោះពុម្ពលើកទី៥០, ២០០៩ ។

[8] មាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, ច្បាប់វិសោធនកម្ម ។

[9] *Prosecutor v. Lubanga*, សេចក្តីសម្រេចស្តីពីទម្លាប់នៃការអនុវត្តនៃការធ្វើឱ្យស្គាល់សាក្សី និងការផ្តល់តឹកតាងរបស់សាក្សី, ICC-01/04-01/06, សាលក្រម ចុះថ្ងៃទី៨ វិច្ឆិកា ២០០៦, កថាខ័ណ្ឌទី៤២ ។ *Prosecutor v. Lubanga*, សេចក្តីសម្រេចទាក់ទិននឹងទម្លាប់នៃការអនុវត្តដែលបានប្រើដើម្បីត្រៀមរៀបចំ និងធ្វើឱ្យស្គាល់សាក្សី សម្រាប់ការផ្តល់សក្ខីកម្មនៅពេលសវនាការ, ICC-01/04-01/06, សាលក្រម ចុះថ្ងៃទី៣០ វិច្ឆិកា ២០០៧, កថាខ័ណ្ឌទី៥៧ ។

តុលាការបានសម្រេចថា ទោះបីជាទម្លាប់នៃការអនុវត្តអំពីការផ្តល់សក្ខីកម្ម ត្រូវបានបង្កើតឡើងនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់តែគោលបំណងនេះក៏ដោយ ក៏ទម្លាប់នៃការអនុវត្តជាសកលមិនអាចឲ្យគេរកបាននៅក្នុងប្រព័ន្ធជាតិដែរ[10]។ គេត្រូវកត់សំគាល់ថាតុលាការព្រហ្មទណ្ឌពិសេសទាំង៣ដែលបានអនុម័តយកការប្រើប្រាស់ទម្លាប់នៃការអនុវត្តនេះ បានផ្អែកលើប្រព័ន្ធច្បាប់ "ជំរុញពីភាគី" ជាធម្មតាដោយហេតុតែតុលាការ ICC បានបញ្ចូលលក្ខណៈទ្រង់ទ្រាយនៃច្បាប់ស៊ីវិលជាច្រើន។

១៣. នៅឯតុលាការពិសេសនានា ការអនុវត្តដែលឲ្យសាក្សីជាអ្នកផ្តល់សក្ខីកម្ម គឺតែងតែជាប្រភពដែលត្រូវបានគេលើកយកមកធ្វើការពិភាក្សាដេញដោលជានិច្ច[11] ដោយសារម្យ៉ាងមកពីតុលាការនោះត្រៀមរៀបចំសាក្សីប្រកបដោយប្រសិទ្ធភាពជាង សម្រាប់ការផ្តល់សក្ខីកម្មរបស់ខ្លួន នាពេលសវនាការ ហេតុដូចនេះ ធ្វើឲ្យសវនាការប្រព្រឹត្តទៅបានដោយឆាប់រហ័ស[12] ហើយមួយវិញទៀតការធ្វើសម្ភាសន៍បែបនេះរវាងភាគីនានា និងសាក្សី ឬអ្នកជំនាញ អាចត្រូវបានគេយកមកប្រើ ដើម្បីព្យាយាម "ធ្វើឲ្យមានឥទ្ធិពលទៅលើខ្លឹមសារនៃ (ចម្លើយសាក្សីនានា) ក្នុងការធ្វើឲ្យមានការបិទបាំង ឬមួលបង្កាច់ចំពោះការពិតជានិច្ច"[13]។

## គ. ក្តីកង្វល់ជាក់លាក់អំពីការរំលឹកការចងចាំរបស់សាក្សីដោយភាគី

១៤. សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា ជំហរទាំងពីរនេះគឺសុទ្ធតែមានសុពលភាព។ ការរំឭកឡើងវិញនូវការចងចាំរបស់សាក្សីដូចជាអំពីចម្លើយនានារបស់ខ្លួនផ្ទាល់ ឬអំពីឯកសារទាំងឡាយដែលទាក់ទងទៅនឹងព្រឹត្តការណ៍នានានៅក្នុងអម្លុងពេលជាង៣ទសវត្សរ៍មកហើយនោះ គឺជាកាតព្វកិច្ចដែលត្រូវធ្វើឲ្យសាក្សី និងអ្នកជំនាញទាំងឡាយរំលឹកឡើងវិញក្នុងលក្ខណៈល្អិតល្អន់ និងឲ្យបានឆាប់រហ័សជាងនៅក្នុងបន្ទប់សវនាការជាផ្លូវការ។ ប៉ុន្តែក្នុងពេលជាមួយគ្នានោះ បើសិនជាភាគីនានាបានចូលរួមនៅក្នុងនីតិវិធីមួយដែលមិនមានការចែងបញ្ញត្តិអំពី ("ការរំឭកឡើងវិញ") នូវការចងចាំរបស់សាក្សី ឬអ្នកជំនាញនោះ គឺនីតិវិធីនោះមានឥទ្ធិពលជាធម្មជាតិ ហើយជាញឹកញាយ តែងតែមានចេតនាក្នុងការប្រើឥទ្ធិពលទៅលើចម្លើយសាក្សី ដែលស្របគ្នាជាមួយនឹងករណីរបស់ភាគីនានា។ អាស្រ័យហេតុនេះ លុះត្រាតែមានការដាក់ឲ្យអនុវត្តនូវប្រព័ន្ធដ៏តឹងរ៉ឹង

---

[10] *Prosecutor v. Lubanga*, សេចក្តីសម្រេចស្តីពីទម្លាប់នៃការអនុវត្តនៃការធ្វើឲ្យស្គាល់សាក្សី និងការផ្តល់តឹកតាងរបស់សាក្សី, ICC-01/04-01/06, សាលក្រម ចុះថ្ងៃទី៨ វិច្ឆិកា ២០០៦, កថាខ័ណ្ឌទី៣៣ ។

[11] Jordash, W. "ទម្លាប់នៃការអនុវត្ត "ការផ្តល់តឹកតាង" នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិៈ ហេតុដូម្តេចបានជាតុលាការព្រហ្មទណ្ឌអន្តរជាតិគួរតែហាមឃាត់ទម្លាប់នៃការអនុវត្តនេះ", *Leiden Journal of International Law*, 22 (2009) 501-523

[12] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* *Milutinović* *និងគូកន*, ញត្តិស្នើសុំឲ្យហាមឃាត់ការផ្តល់សក្ខីកម្មរបស់សាក្សី (Motion to Prohibit Witness Proofing), សំណុំរឿងលេខ IT-05-87-T, សាលក្រម ចុះថ្ងៃទី១២ ធ្នូ២០០៦, ត្រង់កថាខណ្ឌទី១៦ និងកថាខណ្ឌទី២២។

[13] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Karemera និងគូកន*, សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្គំស្តីពីការផ្តល់សក្ខីកម្មរបស់សាក្សី (Witness Proofing), សំណុំរឿងលេខ IT-05-87-T, សាលក្រម ចុះថ្ងៃទី១១ ឧសភា ២០០៧, ត្រង់កថាខណ្ឌទី៨។

មួយដើម្បីធានាថា សវនាការផ្តល់សក្ខីកម្មរបស់សាក្សីបែបនេះ ត្រូវបានដឹកនាំធ្វើយ៉ាងត្រឹមត្រូវ ដែលមានហានិភ័យមួយយ៉ាងពិតប្រាកដថា ឥទ្ធិពលមិនត្រឹមត្រូវអាចត្រូវបានដាក់ទៅលើសាក្សី ឬអ្នកជំនាញទាំងនោះដោយភាគី។

១៥. ក្រៅពីការខ្វះមូលដ្ឋានខាងអង្គច្បាប់ដើម្បីអនុញ្ញាតឱ្យមាន សហព្រះរាជអាជ្ញាបានកត់សំគាល់ឃើញផងដែរថា ការលំបាកផ្នែកភស្តុភារ និងបទបញ្ញាដែលតម្រូវដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីធានាថា សវនាការផ្តល់សក្ខីកម្មរបស់សាក្សី ត្រូវបានធ្វើឡើងដោយត្រឹមត្រូវ និងដោយមានប្រសិទ្ធភាព ដោយមានការគោរពដល់សិទ្ធិរបស់ជនរងគ្រោះ សាក្សី និងជនជាប់ចោទ។ សហព្រះរាជអាជ្ញា យល់ឃើញថា ការដាក់បញ្ចូលនូវនីតិវិធីនេះនៅក្នុងដំណាក់កាលនេះនៃដំណើរការនីតិវិធី គឺមុខជានឹងមិនមានភាពសាមញ្ញ ហើយទំនងជានឹងបង្កើតនូវភាពស្មុគស្មាញជាដុំកំភួនដែលទាក់ទងនឹងសិទ្ធិរបស់ភាគីនានានៅក្នុងនិតិវិធីនោះ។

១៦. សំអាងរបស់មេធាវីការពារក្តីដែលថា ការស្តាប់ចម្លើយសាក្សីនៅមុនការជំនុំជម្រះក្តី គួរត្រូវបានអនុញ្ញាត ដើម្បីធានាពីសមភាពនៃមធ្យោបាយតទល់ក្តី រវាងមេធាវីការពារក្តី និងសហព្រះរាជអាជ្ញា ពីព្រោះពួកគេត្រូវបានអនុញ្ញាតឱ្យជួបសាក្សីសក្តានុពលនានាក្នុងអំឡុងពេលនៃការស៊ើបអង្កេតបឋម ដែលក្រៅតែពីមិនត្រូវបានគាំទ្រតាមផ្លូវច្បាប់ គឺនៅមិនមានមូលដ្ឋានសំអាងទេ។ នៅក្នុងការស៊ើបអង្កេតបឋមនៅក្នុងករណីនេះ សហព្រះរាជអាជ្ញាបានសម្ភាសមនុស្សមិនលើសពី២០នាក់ ដែលភាគច្រើនបានផ្តល់ភ័ស្តុតាងទាក់ទងនឹងមន្ទីរស-២១។ ដោយការចងចាំនៅក្នុងចិត្តថា ទំហំនៃករណីនេះ គឺមិនអាចត្រូវបាននិយាយថា សហព្រះរាជអាជ្ញាត្រូវបានដាក់ឱ្យឋិតនៅក្នុងមុខតំណែងមួយដ៏សំខាន់យ៉ាងខ្លាំងជាងមេធាវីការពារក្តី តាមរយៈការសម្ភាសន៍សាក្សីរហូតដល់២០នាក់ដែលនៅក្នុងចំណោមនោះទេ ដែលព័ត៌មានទាំងស្រុងបានមកពីការសម្ភាសន៍ទាំងនោះត្រូវបានបង្ហាញជូនមេធាវីការពារក្តី តាមរយៈសំណុំរឿង។

១៧. ក្តីកង្វល់ទី២ អំពីការផ្តល់សក្ខីកម្មរបស់សាក្សីពីសំណាក់ភាគីនានានៅមុនពេលសវនាការ គឺទាក់ទងទៅនឹងការបង្ហាញព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយនឹងសាក្សីទាំងនេះ។ ដូចដែលមេធាវីការពារក្តីអន្តរជាតិធ្លាប់បានថ្លែងរួចមកហើយនៅក្នុងករណីពីមុនមួយថា នីតិវិធីបែបដូច្នេះអាចបង្កើតបានជាព័ត៌មានដោយភាគីនានា ដែលត្រូវការជាចាំបាច់ឱ្យមានការដាក់បង្ហាញចំពោះអ្នកដទៃទៀត ហើយដោយចៀសមិនរួចនោះ គឺវានឹងត្រូវបានដាក់បង្ហាញដោយការយឺតយូរ នៅពេលក្រោយបង្កើតបានជាភាពមិនត្រឹមត្រូវចំពោះភាគីដទៃទៀត។ គាត់បានបញ្ជាក់ពីកង្វល់របស់គាត់អំពីការផ្តល់សក្ខីកម្មរបស់សាក្សីនានាតាមរបៀបនេះថា៖

"ក្តីកង្វល់ជាចម្បងរបស់យើង គឺថាវគ្គផ្តល់សក្ខីកម្មនានា ជាពិសេសជាមួយសាក្សីចំនួន៩២នាក់លើកទី៣ គឺជាការវិលទៅរកចម្លើយថ្មីទាំងស្រុង ហើយអ្វីដែលការចោទប្រកាន់កំពុងតែធ្វើនោះគឺពេលឥឡូវនេះ ពួកគាត់មានភ័ស្តុតាងមួយចំនួនដែលធ្លាប់បានទទួលមក ហើយពួកគាត់ចង់គាំទ្រ

លើករណីរបស់ពួកគាត់។ ពួកគាត់កំពុងតែប្រើប្រាស់នូវកាលានុវត្តភាព ដើម្បីស្តាប់ចម្លើយថ្មីមួយទាំងស្រុង”[14]។

១៨. ការព្រួយបារម្ភដែលបានលើកឡើងដោយមេធាវីការពារក្តីរបស់ អៀង សារី នៅក្នុងករណីពីមុនមកសុទ្ធតែមានសុពលភាពដែរ។ អង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រូវតែធានាថា សវនាការផ្តល់សក្ខីកម្មរបស់សាក្សី ដែលបានដឹកនាំដោយភាគីនានាតាមពិត គឺមិនត្រូវបានបើកធ្វើជាថ្មីឡើងវិញទៀតទេ នីតិវិធីនៃការសើបសួរដែលគ្មានការត្រួតមើលពីលើ ដោយអង្គជំនុំជម្រះសាលាដំបូងតាមរយៈភាគីនានា និងដែលមិនស្ថិតនៅក្រោមការអនុញ្ញាតតាមផ្លូវច្បាប់ ដូចដែលមានចែងនៅក្នុងមាត្រា៩៤នៃវិធានផ្ទៃក្នុង។ បើសិនជាទទួលបាននូវព័ត៌មានថ្មី គឺតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងត្រូវតែធានាថា ព័ត៌មាននោះត្រូវបានជូនដំណឹងទៅដល់គ្រប់ភាគីទាំងអស់ ដើម្បីធ្វើឲ្យពួកគេមានលក្ខណៈស្មើភាពគ្នានៅក្នុងការពិនិត្យទៅលើភស្តុតាងនៅក្នុងតុលាការ។

## ឃ. សេចក្តីត្រូវការប្រព័ន្ធសត្យានុម័តស្តីពីការរំលឹកការចងចាំរបស់សាក្សី និងអ្នកជំនាញមុនពេលផ្តល់សក្ខីកម្ម

១៩. ការណ៍ដែលបាននិយាយដូច្នោះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ប្រព័ន្ធសត្យានុម័តមួយស្តីពីការរំលឹកការចងចាំរបស់សាក្សី ត្រង់កន្លែងភស្តុតាងណាដែលពួកគាត់ត្រូវបានរំពឹងថានឹងផ្តល់សក្ខីកម្មនោះ នឹងធ្វើជាវិភាគទានមួយដ៏សំខាន់ ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការស្វែងរកការពិត និងក្នុងការធានាថាការកាត់សេចក្តីនេះ គឺមានលក្ខណៈត្រឹមត្រូវ និងឆាប់រហ័ស។ សាក្សីទាំងឡាយកំពុងត្រូវបានរំពឹងថានឹងផ្តល់សក្ខីកម្មលើព្រឹត្តិការណ៍នានា ដែលបានកើតឡើងប្រមាណ៣៥ឆ្នាំកន្លងមកហើយនេះ នៅក្នុងសាលសវនាការមួយ ដែលអាចនឹងមានលក្ខណៈជាការបំភិតបំភ័យ សូម្បីតែចំពោះសាក្សីដែលមានការទុកចិត្តបំផុតក៏ដោយ។ បើសាក្សីត្រូវបាន ផ្តល់នូវពេលវេលាចំនួនមួយថ្ងៃ ដើម្បីអានចម្លើយនានារបស់ខ្លួនពីមុនៗ, ពិនិត្យមើលឯកសារពាក់ព័ន្ធនានា, រូបថត, វត្ថុតាងជាវីដេអូ និងផែនទី, ការណ៍នេះមុខជានឹងបានជួយសាក្សីយ៉ាងច្បាស់លាស់នៅក្នុងគុណភាពនៃភស្តុតាងរបស់សាក្សីរូបនោះ ដែលនឹងត្រូវធ្វើការផ្តល់ជូននៅក្នុងសាលសវនាការ។ “ការស្គាល់ច្បាស់” នូវនីតិវិធីរមួយ អាចនឹងត្រូវបានត្រួតពិនិត្យ ដោយអង្គជំនុំជម្រះសាលាដំបូងតាមរយៈមន្ត្រីផ្លូវការផ្នែកច្បាប់របស់ខ្លួន ដោយរួមជាមួយនឹងអង្គភាពជនរងគ្រោះ និងអង្គភាពគាំទ្រអ្នកជំនាញ។ ការណ៍នេះនឹងធានាពីកម្មវិស័យភាពនៃដំណើរការ និងមិនមានតម្រូវឲ្យមានការអនុវត្តនូវប្រព័ន្ធមួយដែលនាំឲ្យមានការស្តាប់ចម្លើយភាគីថ្មី ដែលមានលក្ខណៈផ្ទុយទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ទម្លាប់នៃការអនុវត្តដូច្នេះគួរអនុវត្តចំពោះសាក្សីទាំងអស់ រួមទាំងសាក្សីចរិតលក្ខណៈ។

[14] *រដ្ឋអាជ្ញា ទល់នឹង Prlic´*, សំណុំរឿងលេខ IT-04-74/T, ប្រតិចារឹក, ថ្ងៃទី២២ មីនា ២០០៧, ត្រង់កថាខណ្ឌទី ១៦១៤៩-១៦១៥០ ។

២០. ពាក់ព័ន្ធទៅនឹងអ្នកជំនាញ សក្ខីកម្មរបស់ពួកគេ មុខជានឹងត្រូវបានធ្វើឱ្យប្រសើរឡើង បើអង្គជំនុំជម្រះសាលាដំបូង និងភាគីនានា ដែលតាមរយៈពួកគាត់ អាចនឹងមានលទ្ធភាពផ្តល់ប្រឹក្សាដល់ពួកគាត់ ក្នុងរយៈពេលជាច្រើនខែជាមុន ពីប្រធានបទ និងបញ្ហានានាដែលពួកគាត់ចង់ឱ្យគេសួរអ្នកជំនាញនោះ។ សេចក្តីជូនដំណឹងជាមុនពីឯកសារនានាដែលពួកគាត់ចង់ឱ្យពួកអ្នកជំនាញធ្វើការយោងនៅក្នុងតុលាការ ក៏អាចនឹងត្រូវបានផ្តល់ជូនផងដែរ។ បើពួកអ្នកជំនាញអាចនឹងធ្វើការត្រៀមរៀបចំពាក់ព័ន្ធនឹងបញ្ហា ព្រមទាំងឯកសារជាក់លាក់ នោះគុណភាពនៃសក្ខីកម្មរបស់ពួកគេមុខជានឹងត្រូវបានធ្វើឱ្យប្រសើរឡើងជាមិនខាន។

## ង. គោលការណ៍ជាក់លាក់ដែលផ្តល់ជូនជាអនុសាសន៍

២១. អាស្រ័យហេតុនេះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមភាពនៃសក្ខីកម្មផ្តល់នៅពេលសវនាការកុំឱ្យមានហានិភ័យដែលសាក្សីនឹងទទួលឥទ្ធិពលហួសហេតុដោយភាគីណាមួយ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យអនុម័តយកទម្លាប់នៃការអនុវត្ត"ការធ្វើឱ្យស្គាល់ច្បាស់" ភ័ស្តុតាងរបស់សាក្សី និងអ្នកជំនាញ ដូចខាងក្រោម៖

(ក) ក្រោមការត្រួតពិនិត្យរបស់អង្គជំនុំជម្រះសាលាដំបូង សាក្សី ឬអ្នកជំនាញ ត្រូវអនុញ្ញាតយ៉ាងហោចណាស់មួយថ្ងៃពេញ មុនពេលអានសក្ខីកម្មរបស់គាត់ពីមុន កំណត់ហេតុរបស់ពួកគាត់ ឯកសារពាក់ព័ន្ធ មើលរូបថត ខ្សែវីឌីអូ ឬផែនទី ដើម្បីរំលឹកការចងចាំរបស់ពួកគាត់អំពីសក្ខីកម្មដែលពួកគេចង់ឱ្យគាត់ផ្តល់។

(ខ) អង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតឱ្យគូភាគីផ្តល់បញ្ជីឯកសារពាក់ព័ន្ធ រូបថត ខ្សែវីឌីអូ ឬផែនទី ដែលពួកគេចង់ឱ្យសាក្សី ឬអ្នកជំនាញ ពិនិត្យមើលមុនពេលផ្តល់សក្ខីកម្មរបស់ពួកគាត់។

(គ) ទាក់ទងនឹងអ្នកជំនាញ អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាត (i) ឱ្យមានការជូនដំណឹងអំពីឯកសារពាក់ព័ន្ធនានាដូចបានកំណត់ក្នុងចំណុច(ក) ដែលភាគីនានាចង់ឱ្យពួកគេធ្វើការពិនិត្យឡើងវិញឱ្យបានច្រើនសប្តាហ៍ និងច្រើនខែជាមុន អំពីសក្ខីកម្មរបស់ពួកគាត់ និង(ii) អនុញ្ញាតឱ្យភាគីនានាផ្តល់ជូនផងដែរ នូវបញ្ជីឈ្មោះប្រធានបទនានា និងប្រធានបទតូចៗជាមុន ដែលពួកគេមានបំណងចង់សួរសាក្សី ឬអ្នកជំនាញ ដើម្បីឱ្យសាក្សី និងអ្នកជំនាញអាចយកបញ្ហាទាំងនោះទៅពិចារណា ក្នុងពេលត្រៀមរៀបចំរបស់ពួកគាត់។

២២. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការរៀបចំសាក្សី និងអ្នកជំនាញនានា តាមរបៀបបែបដូច្នេះ នឹងបានសម្រេចដល់គោលបំណងនានាដែលមេធាវីការពារក្តីបានលើកឡើង នៅក្នុងសំណើនេះ ដែលស្របពេលជាមួយគ្នា បានធានាថាការត្រៀមរៀបចំបែបដូច្នេះ គឺត្រូវបានធ្វើឡើងតាមរបៀបមួយ ដែលមានលក្ខណៈត្រឹមត្រូវ និងចំតាមគោលដៅ។

## IV. ដំណោះស្រាយដែលស្នើសុំ

២៣. អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើឲ្យ អង្គជំនុំជម្រះសាលាដំបូងបដិសេធចោល នូវសំណើរបស់មេធាវីការពារក្តីលើពាក្យពេជន៍នានាដែលបានស្នើសុំ និងទទួលយកតាមនូវនីតិវិធីនានាដែលបានលើកឡើងជាគោលនៅក្នុងសំណើនេះ ដែលពាក់ព័ន្ធនឹងរយៈពេលនៃសេចក្តីសន្និដ្ឋានអំពីការចោទប្រកាន់ និងការរៀបចំសាក្សី និងអ្នកជំនាញ សម្រាប់សវនាការ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** William SMITH សហព្រះរាជអាជ្ញារង | | |